ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍២៩វិច្ឆិកា

## រយៈពេល ៣ឆ្នាំ ឆ្នាំ២០១៩ - ឆ្នាំ២០២២

ឈ្មោះសហគមន៍នេសាទ ៖ **២៩វិច្ឆិកា**

| | |
|---|---|
| ភូមិ | ៖ សោយ១ សោយ២ កោះផល ព្រែកក្រូច និងអំពិល |
| ឃុំ | ៖ ប៉ឺស១ |
| ស្រុក | ៖ ក្រូចឆ្មារ |
| ខេត្ត | ៖ ត្បូងឃ្មុំ |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍២៩វិច្ឆិកា
# រយៈពេល ៣ឆ្នាំ ឆ្នាំ២០១៩ - ឆ្នាំ២០២២

ឈ្មោះសហគមន៍នេសាទ ៖ **២៩វិច្ឆិកា**

ភូមិ ៖ សោយ១ សោយ២ កោះផល ព្រែកក្រូច និងអំពិល

ឃុំ ៖ ប៊ឹស១

ស្រុក ៖ ក្រូចឆ្មារ

ខេត្ត ៖ ត្បូងឃ្មុំ

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ..........១

ខ- មុខរបរ..........១

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង..........២

ខ- ដែននេសាទ..........២

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស..........៣

ឃ- ធនធានជលផល..........៣

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ..........៣

ខ- ឧបករណ៍នេសាទ..........៤

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ..........៤

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

**ក- ទស្សនៈវិស័យ..........៥**

**ខ- គោលបំណង..........៥**

**គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ..........៥

គ២- ផែនការកែលំអដែននេសាទ..........៧

គ៣- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស..........៧

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក..........៨

គ៥- ផែនការទប់ស្កាត់បទល្មើសនេសាទ..........៩

គ៦- ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ..........៩

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល..........៩

គ៨- ផែនការរៀបចំសាងសង់ស្នាក់ការឡើងវិញ..........១០

**ឃ. ផែនការយុទ្ធសាស្ត្រ..........១១**

**- តារាងសង្ខបផែនការ..........១៣**

**- តារាងកម្មវិធីការងារ..........១៥**

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ**២៩វិច្ឆិកា** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨។

សហគមន៍នេសាទ២៩វិច្ឆិកាមានទីតាំងស្ថិតនៅភូមិកោះផល ឃុំបើស១ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ ដែលមានសមាជិកសរុបចំនួន៨០៨នាក់ ប្រុស៤១៦នាក់ ស្រី៣៩២នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន១៥៥គ្រួសារ។ មានគណៈ កម្មការចំនួន១១នាក់ ស្ត្រីចំនួន០៣នាក់។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការ សហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ និងធ្វើផែនទី
- ចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន៧,៨៧២នាក់ ប្រុស៣,៧៨៩នាក់ ស្រី៤,០៨៣នាក់ ស្មើនឹង១,៦៦៥គ្រួសារ។ មានជនជាតិខ្មែរចំនួន៨៤១នាក់ និងជនជាតិអ៊ីស្លាមចំនួន៧,៧៨៨នាក់។

-ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០ភាគរយ។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាមចំនួន៩០ភាគរយ

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន២៧៤នាក់ ស្រី១៤៦ នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៥០៨នាក់ ស្រី១៨នាក់ កម្រិតមធ្យមសិក្សាចំនួន ២៦នាក់ ស្រី៤នាក់

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន១៣នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ២០នាក់ ស្រី០៦នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣០នាក់ ស្រី១០នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៦នាក់ ស្រី៣នាក់

-ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន៥នាក់ ស្រី២នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេះរួមមាន៖

-ធ្វើនេសាទចំនួន១៨២ គ្រួសារ

-ធ្វើស្រែចំនួន១៣៥៣ គ្រួសារ ទំហំ៩៣៧ ហិកតា

-ធ្វើវារីវប្បកម្មចំនួន៩៦គ្រួសារ ស្រះចំនួន១៤ស្រះ ទំហំ ៣០មx៤០ម បែត្រីចំនួន៨៦បែ ទំហំ ១,៥មx២,៥ម

-ដាំបន្លែចំនួន ០៣គ្រួសារ ទំហំ០,៥០ហិកតា

-ជាងផ្ទះចំនួន ៨០គ្រួសារ

-លក់ដូរចំនួន៥០គ្រួសារ

-កម្មករចំណាកស្រុក ១,១០០ នាក់

-ចិញ្ចឹមសត្វ ១២គ្រួសារ

-កែច្នៃផលិតផលជលផល០៣គ្រួសារ

-ប្រាក់ចំណូលជាមធ្យមក្នុង០១គ្រួសារប្រចាំឆ្នាំមានចំនួន ៩,០០០,០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍២៩វិច្ឆិកា ត្រូវលុបចេញពីអតីតឡូត៍នេសាទលេខ១០ ដែននេសាទទឹកសាប ក្នុងខេត្តត្បូងឃ្មុំ មានទំហំ ៥១១ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

-ខាងជើងទល់នឹង ៖ ទន្លេមេគង្គ

-ខាងត្បូងទល់នឹង ៖ ឃុំឈូក និងឃុំទួលស្នួល ស្រុកក្រូចឆ្មារ

-ខាងកើតទល់នឹង ៖ ភូមិទី៧ ឃុំរការខ្នុរ ស្រុកក្រូចឆ្មារ

-ខាងលិចទល់នឹង ៖ ភូមិអំពិល ឃុំប៊ុស២ ស្រុកក្រូចឆ្មារ

មាននិយាមកាដូចខាងក្រោម៖

| ចំណុចអាប់ស៊ីស | ចំណុចអរដោនេ |
|---|---|
| ៥៧៧៨៩២ | ១៣៥៣៨២៥ |
| ៥៧៧៤៨៦ | ១៣៤៩៥៦២ |
| ៥៧៨៣៨៩ | ១៣៤៨៨២៦ |
| ៥៧៩៧១២ | ១៣៤៨៦២៣ |
| ៥៨០៤៤១ | ១៣៤៨៧៣៣ |
| ៥៨០៩៦៦ | ១៣៥៣១៩១ |

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទ២៩វិច្ឆិកា មានបឹងចំនួន២បឹងគឺ៖

-បឹងជ្រលក់ ទំហំ ៥ហិកតា នេសាទពីពេញមួយឆ្នាំ

-បឹងក្រពើត្អូក ទំហំ២,៥ ហិកតា នេសាទពីពេញមួយឆ្នាំ
-បឹងទឹកវិញ (ព្រែកតូច)ទំហំ៥ ហិកតា នេសាទពីខែ០៩ ដល់ខែ០២
-អូរកាហែរ មានទំហំ១០,៥ហិកតា នេសាទពីខែ០៩ ដល់ខែ០២។

**ឃ. ធនធានផលផល**

- **ប្រភេទត្រី ៖**

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្ពោរ ត្រីឆ្លាំង ត្រីកែស ត្រីឆ្ដោក ត្រីក្អែក ត្រីគ្រសក់ ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឫស្សី ត្រីកន្ធ្រប់ ក្ដាំងហាយ ត្រីខ្នាន់ ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្នឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាវក្ដាម ត្រីលលកសរ ត្រីឆ្ពិន ត្រីជញ្ជក់ ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្ដាតឆ្កែ កំពិស ។

- **ប្រភេទវារីសត្វ ៖**

អណ្ដើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស(ខ្យងពណ៌លឿង) ក្ដាម អន្ទង់ ខ្ចៅគូចស្រួចខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖**

ដើមថ្លើមអណ្ដើក ខ្លបយក្ស(អួយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លើង អញ្ចាញ ត្នួ កន្ទ្រេង ស្នែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ត្នួ ខ្លាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្នើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហែ ស្មោ ស្លត បន្លាឃ្លេ ថ្វាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្ដៅ ភ្នែកក្រាប វល្លិ៍អណ្ដាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចម៍មាន់ ព្រលិតដូង រំចង់ ស្ពន់អំបោះ ត្រាវអណ្ដែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំបួង កក់ជ្រុង កក់ក្ដាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្នាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ ៖**

-អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៥៥នាក់ ស្រី ២១នាក់
-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៧៣នាក់ ស្រី២៤នាក់
-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៥០នាក់ ស្រី១១នាក់។

**ខ. ឧបករណ៍នេសាទ ៖**

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ត្បូង | ៣០៦ | ១.៤០០ម/គ្រួសារ | ៤២៨,៤០០ម | ពេញមួយឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| សន្ទូចរនង | ផ្លែ | ១០០ | ៥០០ផ្លែ/គ្រួសារ | ៥០,០០០ផ្លែ | ខែកក្កដា - ខែវិច្ឆិកា |
| លបត្រី | គ្រឿង | ២០ | ២០គ្រឿង/គ្រួសារ | ៤០០គ្រឿង | ខែកក្កដា - ខែកុម្ភៈ |
| លបកំពិស | គ្រឿង | ៣០ | ២០០គ្រឿង/គ្រួសារ | ៦,០០០គ្រឿង | ខែកក្កដា - ខែមេសា |
| សំណាញ់ | វង់ | ៤១ | ២វង់/គ្រួសារ | ៨២វង់ | ពេញមួយឆ្នាំ |
| បបក់ | គ្រឿង | ៦ | ១គ្រឿង/គ្រួសារ | ៦គ្រឿង | ខែធ្នូ - ខែឧសភា |
| អង្រុត | គ្រឿង | ២៥ | ១គ្រឿង/គ្រួសារ | ២៥គ្រឿង | ខែកក្កដា - ខែមេសា |
| អួនអូសដៃ | វង់ | ២៥ | ៥០ម/គ្រួសារ | ២៥វង់ | ខែកុម្ភៈ - ខែឧសភា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥០គ្រឿង | ២០០-១,០០០គីឡូក្រាម | ៣,៥-១៥សេះ |
| ទូកអុំ និងចែវ | ៥០គ្រឿង | ១២០-៥០០ គីឡូក្រាម | |

-ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ត្បូង | ៤៧៥ | ១.០៥០ម/គ្រួសារ | ៤៩៨,៧៥០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៩៧ | ៥០០ផ្លែ/គ្រួសារ | ៤៨,៥០០ផ្លែ | ខែកក្កដា - ខែវិច្ឆិកា |
| លបត្រី | គ្រឿង | ៧៦ | ១០គ្រឿង/គ្រួសារ | ៧៦០គ្រឿង | ខែកក្កដា - ខែកុម្ភៈ |
| លបកំពឹស | គ្រឿង | ៣២ | ១៥០គ្រឿង/គ្រួសារ | ៤,៨០០គ្រឿង | ខែកក្កដា - ខែមេសា |
| សំណាញ់ | វង់ | ៣៧ | ១វង់/គ្រួសារ | ៣៧វង់ | ពេញមួយឆ្នាំ |
| អួនអូសដៃ | វង់ | ១៥ | ៥០ម/គ្រួសារ | ១៥វង់ | ខែកុម្ភៈ - ខែឧសភា |
| អួនស្បៃមុង | វង់ | ៨ | ២៥០ម/គ្រួសារ | ៨វង់ | ខែកុម្ភៈ - ខែកក្កដា |
| អួនឆក់ត្រជាក់ | វង់ | ៨ | ១៥ម/គ្រួសារ | ៨វង់ | ខែមករា - ខែកក្កដា |
| សំរាស់ | ដុំ | ៣០ | ២៥០ម/គ្រួសារ | ៦០ដុំ | ខែតុលា - ខែកក្កដា |
| ឆក់ក្ដៅ | គ្រឿង | ៩៣ | ១គ្រឿង/គ្រួសារ | ៩៣គ្រឿង | ពេញមួយឆ្នាំ |
| លូស្បៃមុង | គ្រឿង | ១១៧ | ៣គ្រឿង/គ្រួសារ | ៣៥១គ្រឿង | ពេញមួយឆ្នាំ |
| រ៉ាវ | មាត់ | ១៦ | ២មាត់/គ្រួសារ | ៣២មាត់ | ខែកក្ក - ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៥០គ្រឿង | ២០០-១,០០០គីឡូក្រាម | ៤-១៥សេះ |
| ទូកអុំ និងចែវ | ៥០គ្រឿង | ១២០-៥០០ គីឡូក្រាម | គ្មាន |

-ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងពាក់ | ក្បូង | ២០ | ១,០៥០ម/គ្រួសារ | ២១,០០០ម | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៥ | ៥០០ផ្លែ/គ្រួសារ | ២,៥០០ផ្លែ | ខែកក្កដា - ខែវិច្ឆិកា |
| សន្ទូចបង្កៃ | ផ្លែ | ១០ | ៥០ផ្លែ/គ្រួសារ | ៥០០ផ្លែ | ខែកក្កដា - ខែវិច្ឆិកា |
| សំណាញ់ | វង់ | ៥ | ១វង់/គ្រួសារ | ៥វង់ | ពេញមួយឆ្នាំ |
| អួនអូសដៃ | វង់ | ១០ | ២ដុំ/គ្រួសារ | ៦០ដុំ | ខែតុលា - ខែកក្កដា |
| ឆក់ក្តៅ | គ្រឿង | ១០ | ១គ្រឿង/គ្រួសារ | ១០គ្រឿង | ពេញមួយឆ្នាំ |
| រ៉ាវ | មាត់ | ៤ | ៣មាត់/គ្រួសារ | ១២មាត់ | ខែកក្កដា - ខែមេសា |
| លាន់ | គ្រឿង | ១០ | ៥០គ្រឿង/គ្រួសារ | ៥០០គ្រឿង | ខែកុម្ភៈ - ខែកក្កដា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៦៣ | ២០០-១,០០០ | ៤-១៥សេះ |
| | | | |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ ( គិតជា គក ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី ចំរុះ | ៦០០គីឡូក្រាម | ៤០០គីឡូក្រាម | ១,០០០គីឡូក្រាម |
| | | | |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

**ក. ទស្សនៈវិស័យ ៖**

សហគមន៍នេសាទ**២៩វិច្ឆិកា** មានទស្សនៈវិស័យចូលរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ខ. គោលបំណង ៖**

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការច្នៃប្រឌិត
-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

**គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងជ្រលក់ | ខែតុលា - ឧសភា | មង | ១៥០ម/គ្រួសារ | ៨៦គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ខែកក្កដា - ខែវិច្ឆិកា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥០គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | សន្ទូចបង្កៃ | ៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | សំណាញ់ | ១គ្រឿង/គ្រួសារ | ១៥គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | ទ្រូ | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | ឈ្នងជញ្ជាត់ | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | ភាវលៀស | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | ថ្នងដងកំពិស | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ខែធ្នូ - ខែឧសភា | បបក់ | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ពេញមួយឆ្នាំ | អង្រុត | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| បឹងក្រពើក្អក | ខែតុលា - ឧសភា | មង | ១៥០ម/គ្រួសារ | ៨៦គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| | ខែកក្កដា - ខែវិច្ឆិកា | សន្ទូចរនង | ២០០ផ្លែ/គ្រួសារ | ៥០គ្រួសារ | អ្នកនេសាទជាសមាជិក |

| | | | | |
|---|---|---|---|---|
| | | | | អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | សន្ទូចបង្កៃ | ៥០ផ្លែ/គ្រួសារ | ៥គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ខែមិថុនា - ខែកុម្ភៈ | លបត្រី | ៧គ្រឿង/គ្រួសារ | ១៥គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | លបកំពិស | ៥០គ្រឿង/គ្រួសារ | ២០គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | សំណាញ់ | ១គ្រឿង/គ្រួសារ | ១៥គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | ទ្រូ | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ខែមិថុនា - ខែសីហា | លាន់ | ៥០គ្រឿង/គ្រួសារ | ១០គ្រួសារ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | ឈ្នាងជញ្ជាត់ | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | រាវលៀស | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | ផ្ទងកំពិស | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ខែធ្នូ - ខែឧសភា | បបក់ | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |
| ពេញមួយឆ្នាំ | អង្រុត | មិនកំណត់ | មិនកំណត់ | អ្នកនេសាទជាសមាជិក<br>អ្នកនេសាទខាងក្នុងនិងខាងក្រៅ |

**គ.២ ផែនការកែលំអដែននេសាទ**

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម - បញ្ចប់ |
|---|---|---|---|---|---|
| បឹងជ្រលក់ | ២ហិកតា | ២ហិកតា | -គ្រឿងចក្រស្តារឡើងវិញឬ ម៉ាស៊ីនបូមដី<br>-លើកទំនប់ស្ទាក់មុខទឹកកុំអោយហូរចុះទៅក្រោមពេលរដូវប្រាំង<br>-ប្រជុំផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ៥,០០០ | ២០១៩ - ២០២១ |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងជ្រលក់ | ២ ហិកតា | ត្រីមេពូជ ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ២ដង/ឆ្នាំ | ៣០០ | ២០១៩ | ២០២២ |
| | | | បោះបង្គោលព្រំតំបន់អភិរក្ស ចំនួន៨បង្គោល | ១,៥០០ | ២០១៩ | ២០២២ |
| | | | ដាក់ស្លាកសញ្ញាចំនួន១ | ១២០ | ២០២០ | |
| | | | ល្បាតការពារជាប្រចាំកន្លែងអភិរក្ស(២ដង/ខែ) | ១,៦២០ | កក្កដា ២០១៩ | កក្កដា ២០២២ |
| | | | -លែងកូនត្រីពោ, ប្រា, រ៉ស់ និង អណ្តែង ២០.០០០កូនក្នុង១ឆ្នាំ<br>-លែងពូជខ្យង ១០០០ គីឡូ/ឆ្នាំ | ១៥,០០០ | ២០១៩ | ២០២២ |
| | | | ចងទ្រនំកំប្លោក រៀងរាល់ឆ្នាំ | ៦០០ | ២០១៩ | ២០២២ |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងជ្រលក់ | ២ហិកតា | ព្រៃលិចទឹក | ផ្សព្វផ្សាយពីកន្លែងព្រៃលិចទឹកឱ្យបានទូលំទូលាយ | ៦០០ | មិនា /២០២០ | មិនា /២០២២ |
| | | | ដាំព្រៃលិចទឹក ចំនួន២.០០០ដើម (រាំង, ត្រស់ និង សណ្តាន់) | ៤,០០០ | មិនា/២០២០ | ឧសភា/២០២២ |
| | | | ថែរក្សា ការពារ | ១,២០០ | រយៈពេល៣ឆ្នាំ | |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន៨ បង្គោល | ១,២០០ | កុម្ភៈ/២០២០ | មេសា/២០២០ |
| | | | ដាក់ស្លាកសញ្ញា ២ | ២០០ | មេសា២០២០ | មេសា២០២០ |

### គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ -ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១,២០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញ | មិនា និងមិថុនា/រៀងរាល់ ឆ្នាំ (៣ឆ្នាំ) | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំត្រីមាស | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ -មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តការងារ | ១,២០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋានអង្គភាពពាក់ព័ន្ធ | រៀងរាល់ខែ និង៣ខែម្ដង | |
| អនុវត្តផែនការ៖ (រៀបចំកំលាំងចុះបង្រ្កាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញា ធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង -ធនធានជលផលកើនឡើង -ជីវភាពសមាជិកស.នធូរធារ | ៣,៦០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | (២ដង/ខែ) ជាប្រចាំ (រយៈពេលបីឆ្នាំ) | |

### គ៦-ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំ | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ -មានផែនការណ៍អនុវត្តបន្ត | ៣៦០ | -គណៈកម្មការ -ក្រុមល្បាត | ១៥/រៀងរាល់ខែ រយៈពេល(៣ឆ្នាំ) | |
| ទិញសម្ភារៈការិយាល័យ | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ៩០ | គណៈកម្មការ | រយៈពេល(៣ឆ្នាំ) | |

### គ៧-ផែនការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាល

ផែនការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **ផែនការផ្សព្វផ្សាយ** | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់ | -សមាជិកសហគមន៍នេសាទ | ៩០០ | គណៈកម្មការ,ស | មេសា/រៀងរាល់ឆ្នាំ | |

| | | | | | |
|---|---|---|---|---|---|
| ផលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ និងបទពិសោធន៍ដែលទទួលបាន | និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធានច្បាប់<br>-ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើន នាំឲ្យជីវភាពធូរធារ | | មាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, អង្គការដៃគូ | (៣ឆ្នាំ) | |
| បិទផ្សាយឯកសារសហគមន៍១ដង/ឆ្នាំ | | | | ខែមករា/ (រាល់ឆ្នាំ) | ខែមករា (រាល់ឆ្នាំ) |
| ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ | | | | មិថុនា (រាល់ឆ្នាំ) | មិថុនា (រាល់ឆ្នាំ) |
| **ផែនការបណ្តុះបណ្តាល** | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល៖<br>-របាយការណ៍<br>-កំណត់ហេតុ<br>-ភាពជាអ្នកដឹកនាំស.ន<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកា និងគ្រប់គ្រងថវិកា | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៥០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ១ដង/ឆ្នាំ មករា រាល់ឆ្នាំ | មករា (រាល់ឆ្នាំ) |
| វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ (៣នាក់) | | គណៈសហគមន៍នេសាទ | ឧសភា-ធ្នូ/២០២០ | |

**គ៨-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | តុលា/២០១៩ (រៀងរាល់ឆ្នាំ) | ខែធ្នូ /២០១៩ | ១០១ | ៥០០រៀល/នាក់ (៣០៦នាក់) |

| | | | | | |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំអ្នកនេសាទជាប្រចាំ ២០,០០០ រៀល/ម្នាក់ អ្នកនេសាទម្តងម្កាល ៥,០០០រៀល/នាក់ និង អ្នកមិននេសាទ១,០០០ រៀល/នាក់ | ខែមករា /២០២០ | ខែធ្នូ /២០២០ | ៤៩១ | -ប្រចាំ៥៥នាក់ ២០,០០០ រៀល/នាក់<br>-ម្តងម្កាល១៨២ នាក់៥,០០០ រៀល/នាក់<br>-មិននេសាទ៣៨ នាក់១,០០០ រៀល/នាក់<br>(រយៈពេល៣ឆ្នាំ) |
| ប្រាក់ចំណូលពីអ្នកនេសាទមិនមែនជាសមាជិកបង់កម្រៃការធ្វើនេសាទ | -ផ្សព្វផ្សាយជូនដំណឹង<br>-ដល់សមាជិកក្រៅស.ន បង់ប្រាក់កម្រៃធ្វើនេសាទ<br>-ធ្វើកិច្ចសន្យានិងប្រមូលកម្រៃនេសាទ | ជាប្រចាំ | | ១៨៧ | ១៥,០០០រៀល/ទូក ៤៥៧ទូករាល់ឆ្នាំ (រយៈពេល ៣ឆ្នាំ) |
| សរសេរគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាល សប្បុរសជន និងអង្គការដៃគូរពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយរដ្ឋាភិបាល និង អង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដាន ដាក់បញ្ចូលផែនការប្រជុំជាមួយឃុំ | ២០១៩ | ២០២២ | ៤៤,១៩០ | |
| **សរុប** | | | | **៤៤,១៩០** | ដោយមិនបានបូលបញ្ចូលចំណូលពីសមាជិក ភាគទានរឺការបង់កម្រៃរបស់អ្នកនេសាទ |

**ឃ. ផែនការយុទ្ធសាស្ត្រ**

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញអង្គការនានាគម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការ ឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

-រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍

-ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

-បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ

-រៀបចំធ្វើស្នាក់ការសហគមន៍នេសាទចំនួនមួយខ្នង និងទិញទូកម៉ាស៊ីនចំនួន១គ្រឿងសម្រាប់គ្រប់គ្រង និងថែរក្សា ការពារកន្លែងនេសាទសហគមន៍

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សាមគ្គីឃុំមៀន រយៈពេល ៣ ឆ្នាំ (ខែកក្កដា ឆ្នាំ២០១៩ ដល់ ខែមិថុនា ឆ្នាំ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ធ្វើនេសាទ | -ត្រីកើន<br>-បង្កើនប្រាក់ចំណូល | | សមាជិកនិងគណៈកម្មការ | ២០១៩ | ២០២២ | |
| ២.ការកែលំអកន្លែងនេសាទសហគមន៍ | -ប្រើគ្រឿងចក្រស្តារ<br>-ស្វែងរកម្ចាស់ជំនួយ<br>-ប្រជុំផ្សព្វផ្សាយ<br>-សាងសង់ទំនប់បង្ហូរ | ត្រីកើន | ៥,០០០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៣.ការកំណត់ និងរៀបចំកន្លែងអភិរក្ស | -ផ្សព្វផ្សាយ<br>-បោះបង្គោល<br>-ដាក់ស្លាកសញ្ញា<br>-ការពារ<br>-លែងកូនត្រី<br>-ចងទ្រនំកំប្លោក | ត្រីកើនឡើងវិញ | ១៩,១៤០ | -ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | -ផ្សព្វផ្សាយ<br>-ដាំព្រៃលិចទឹក<br>-ការពារ<br>-បោះបង្គោល<br>-ដាក់ស្លាកសញ្ញា | -ព្រៃលិចទឹកកើន<br>-ត្រីកើន | ៧,២០០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២១ | |
| ៥.ផែនការទប់ស្កាត់បទល្មើសជលផល | -ប្រជុំផ្សព្វផ្សាយ<br>-ប្រជុំរៀបចំផែនការល្បាត<br>-ចុះអនុវត្តផែនការ | -ធនធានព្រៃលិចទឹក និងជលផលកើនឡើង<br>-ប្រជាពលរដ្ឋមានជីវភាពធូរធារ | ៦,០០០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៦. ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្ម | -ប្រជុំ<br>-ទិញសម្ភារៈការិយាល័យ | -របាយការណ៍លទ្ធផលសម្រេចបាន ប្រចាំខែ<br>-មានសម្ភារៈការិ | ៤៥០ | ស.ន.ស.គ.ឃ.ម | ២០១៩ | ២០២២ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ការស.ន | | យាល់យសម្រាប់ប្រើប្រាស់ | | | | | |
| ៧. ផែនការផ្សព្វផ្សាយ និង បណ្តុះបណ្តាល | -ផ្សព្វផ្សាយ<br>-បិទផ្សាយឯកសារ<br>-ចែកឯកសារ | គណៈកម្មការនិងសមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋមានការយល់ដឹង | ១,៤០០ | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| ៨.ផែនការសាងសង់ស្នាក់ការឡើងវិញ | រុះរើសំណង់បាក់បែក និងស្វែងរកជាងសាងសង់ | គណៈកម្មការ និងសមាជិក | ៥,០០០ | | ២០១៩ | ២០២២ | |
| ៨.ផែនការថវិកាទ្រទ្រង់សហគមន៍នេសាទ | -ប្រមូលភាគទានសមាជិកភាព<br>- ភាគទានប្រចាំឆ្នាំ<br>- កម្រៃពីអ្នកខាងក្រៅ<br>- សរសេរគម្រោងស្នើសុំរាជរដ្ឋាភិបាល សិប្បុរសជន អង្គការនានា | មានថវិកាអនុវត្តសកម្មភាព | | - ស.ន.ស.គ.ឃ.ម<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សប្បុរសជន | ២០១៩ | ២០២២ | |
| សរុប | | | ៤៤,១៩០ | | | | |

## តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ ខែកក្កដា ២០១៩ ដល់ ខែមិថុនា២០២២

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | ២០២១ | | | | | | ២០២២ | | | | |
| | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ... | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ | មីនា | ...... | វិច្ឆិកា | ធ្នូ | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ២.ការកែលំអរកន្លែងនេសាទ ស.ន | | | | | | | x | x | x | | | | | | x | x | x | x | x | x | x | | | |
| ៣.ការកំណត់និងរៀបចំតំបន់អភិរក្ស | x | | | | | | | x | x | x | x | x | x | | | x | x | | | x | x | x | x | x |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | x | x | x | x | x | | | x | x | x | x | x | x | x | x | x | x | x |
| ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | x | x | | x | | x | | x | | x | | x | | x | | x | | x | | x | |
| ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៧.ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៨.ផែនការសាងសង់ស្នាក់ការ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ៩.ផែនការស្វែងរកថវិកាទ្រទ្រង់ ស.ន | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |

សូមគោរពជូន
លោកមេឃុំប៊ឺសរ១
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ប៊ឺសរ១ ថ្ងៃទី ខែ ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទ២៩វិច្ឆិកា

លេខៈ ៣១/២០១៩
បានឃើញនិងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលត្បូងឃ្មុំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ប៊ឺសរ១ ថ្ងៃទី ខែ ឆ្នាំ២០១៩
មេឃុំ លោកមេឃុំប៊ឺសរ១
ណេ ស៊ីម

បានឃើញនិងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ត្បូងឃ្មុំ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៩
នាយផ្នែករដ្ឋបាលជលផលត្បូងឃ្មុំ

លេខៈ
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ
"ដើម្បីជូនពិនិត្យនិងសម្រួល"
ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ត្បូងឃ្មុំថ្ងៃទី ខែ តុលា ឆ្នាំ២០១៩
នាយខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ
អៀម ម៉ាយ៉ូនី

លេខៈ
បានឃើញនិងគោរពជូន
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ"
ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ត្បូងឃ្មុំ ថ្ងៃទី ខែ ឆ្នាំ២០១៩
ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ
ហេង ពិសិដ្ឋ

លេខៈ
បានឃើញនិងឯកភាព
ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
អេង ជាសាន